## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

## សាលក្រមព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌលេខ÷ ២១០៩ អ.ក
ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០
សាលក្រមព្រហ្មទណ្ឌលេខ÷ ០៦ "ខ"
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២

### ក្នុងនាមប្រជារាស្ត្រខ្មែរ
### សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តកណ្ដាល នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោងពីរ និងសាមសិបនាទីរសៀល ដោយមានសមាសភាពចូលរួមដូចតទៅ÷

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណី**

លោក [redacted] និងលោក [redacted]សមាជិកគណៈមេធាវី

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ÷ ២១០៩ អក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ ដែលមានជនជាប់ចោទ÷

១-ឈ្មោះ [redacted]បណ្ឌិត ភេទប្រុស អាយុ២៨ឆ្នាំ (កើតឆ្នាំ១៩៩៣) ជនជាតិខ្មែរ មុខរបរ រកស៊ីខ្សាច់ មានទីកន្លែងកំណើតនៅភូមិ[redacted]ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្នផ្ទះជួលលេខ១៦៨D ផ្លូវជាតិលេខ៥ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]ស្រ៊ុន (រស់) ម្ដាយឈ្មោះ [redacted] ប៊ុណ្ណាត (ស្លាប់) ប្រពន្ធឈ្មោះ[redacted] ច័ន្ទរស្មី កូនគ្មាន ទោសពីមុនគ្មាន ជានីតិជន កម្រិតវប្បធម៌ បរិញ្ញាបត្រ។ (ក្រៅឃុំ)



Scanned with CamScanner

២-ឈ្មោះ [redacted] សុខគង់ ភេទប្រុស អាយុ៣២ឆ្នាំ (កើតឆ្នាំ១៩៨៩) ជនជាតិខ្មែរ មុខរបរ រកស៊ីខ្សាច់ មានទីកន្លែងកំណើតនៅភូ [redacted] ខេត្តកំពង់ចាម និងទីលំនៅសព្វថ្ងៃ ផ្ទះជួលបុរីរតនៈ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ហាន (រស់) ម្តាយឈ្មោះ [redacted] ហុង (រស់) ប្រពន្ធឈ្មោះ [redacted] លីដា (លែងលះ) មានកូន០១នាក់ ជានីតិជន ទោសពីគ្មាន កម្រិតវប្បធម៌ ថ្នាក់ទី១២ ។ (ក្រៅឃុំ)

ជាប់ចោទពីបទ÷ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិព្រែកសំរោង១ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

-មានឈ្មោះ [redacted] លោក [redacted] និងលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ ។

-ដើមបណ្តឹងរដ្ឋប្បវេណី

១.ឈ្មោះ [redacted] កុសល ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅផ្លូវលំ ភូមិព្រែកសំរោង១ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ÷ ៣៤៨ ដកសស.២១ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ÷ ១២៣៩ ដកសព ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាដំណោះស្រាយលេខ÷១៣៤១ ដកដស ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ÷ ១៣៧២ ដកចត/២១ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។

**អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ÷**

កាលពីអំឡុងខែតុលា ឆ្នាំ២០២០ ឈ្មោះ ហាន សុខគង់ ភេទប្រុស និងឈ្មោះ [redacted] បណ្ឌិត ភេទប្រុស បានទទួលម៉ៅការក្នុងការដឹកខ្សាច់សំណង់ឱ្យឈ្មោះ [redacted] កុសល ភេទប្រុស ដោយដឹកពីឃុំព្រែកពោធិ៍ ខេត្តកំពង់ចាម ឆ្ពោះទៅដេប៉ូខ្សាច់នៅភូមិកំពង់ព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល ក្នុងមួយថ្ងៃយ៉ាងតិចបំផុតចំនួន២,០០០(ពីរពាន់)ម៉ែត្រគូប ក្នុងតម្លៃ២.២$ (ពីរចុចពីរ)ដុល្លារអាមេរិកក្នុងមួយម៉ែត្រគូប។ ក្រោយពីឯកភាពព្រមព្រៀងគ្នា ឈ្មោះ [redacted] កុសល ក៏បានប្រគល់ប្រាក់កក់ចំនួន១០,០០០$ (មួយ



Scanned with CamScanner

ម៉ឺន) ដុល្លារអាមេរិក ទៅឱ្យឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ ហើយក៏បានសន្យាថាបីថ្ងៃក្រោយនឹងចាប់ផ្តើមធ្វើការដឹកខ្សាច់យកទៅដាក់នៅដេប៉ូខ្សាច់របស់ឈ្មោះ [redacted] កុសល នៅភូមិកំពង់ព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល។ លុះដល់ថ្ងៃការកំណត់ដឹកខ្សាច់ ស្រាប់តែឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ បានសុំពន្យាពេល ដោយប្រាប់ថាម៉ាស៊ីនបូមខ្សាច់សម្រាប់បាញ់ឡើងកំពុងខូច និងបានខ្ចីប្រាក់ឈ្មោះ [redacted] កុសល បន្ថែមចំនួន៥,០០០$ (ប្រាំពាន់) ដុល្លារអាមេរិក ដើម្បីយកទៅទិញគ្រឿងបន្លាស់ពីប្រទេសវៀតណាម ព្រមទាំងសន្យាថា មួយអាទិត្យទៀតនឹងដឹកខ្សាច់ឱ្យឈ្មោះ [redacted] កុសល។ លុះដល់ថ្ងៃកំណត់ឈ្មោះទាំងពីរនាក់មិនបានដឹកខ្សាច់ឱ្យឈ្មោះ [redacted] កុសល ទេ ហើយថែមទាំងខ្ចីប្រាក់បន្ថែមចំនួន ១០,០០០$ (មួយម៉ឺន) ដុល្លារអាមេរិក ដោយប្រាប់ថាគ្រឿងបន្លាស់ម៉ាស៊ីនបូមខ្សាច់មានតម្លៃថ្លៃ។ បន្ទាប់ពីបានទទួលប្រាក់លើកចុងក្រោយនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០ ឈ្មោះ [redacted] កុសល បានតេទូរស័ព្ទទៅអ្នកទាំងពីរខាងលើ ប៉ុន្តែអ្នកទាំងពីរនោះ មិនព្រមលើកទូរស័ព្ទ និងបានព្យាយាមគេចវេសរហូត ។

## នាពេលសួរចម្លើយ

១-ជនជាប់ចោទ [redacted] បណ្ឌិត បានឆ្លើយថា÷ កាលពីថ្ងៃកើតហេតុ ខ្លួនពិតជាបានឱ្យអ្នកតំណាងឈ្មោះ [redacted] សារ៉េត ធ្វើកិច្ចសន្យាម៉ៅការបូមខ្សាច់ជាមួយឈ្មោះ [redacted] សុខា ជាអ្នកតំណាងឱ្យឈ្មោះ [redacted] កុសល ដោយនៅក្នុងកិច្ចសន្យាបានកំណត់ក្នុង០១ (មួយ) ម៉ែត្រគូប តម្លៃ០.២៧$ (សូន្យចុចម្ភៃប្រាំពីរ) ដុល្លារអាមេរិក ហើយក្នុង០១(មួយ)ថ្ងៃ ត្រូវបូមឱ្យបានចំនួន៥,០០០(ប្រាំពាន់) ម៉ែត្រគូប ប្រសិនបើបូមមិនបានគ្រប់ចំនួនក៏ត្រូវតែគិត៥,០០០(ប្រាំពាន់) ម៉ែត្រគូបដែរ បើគិតជាសាឡាង់បានប្រហែលជា០៤(បួន) ទៅ០៥ (ប្រាំ) តាមទំហំសាឡាង់ជាក់ស្តែង និងបានកំណត់រយៈពេល០២(ពីរ)ឆ្នាំ រួមទាំងត្រូវធ្វើការកក់ប្រាក់ចំនួន១៥,០០០$ (មួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ប្រាកដមែន។ រហូតដល់ពេលបច្ចុប្បន្នខ្លួនបានទទួលប្រាក់ពីឈ្មោះ [redacted] កុសល ចំនួន២៣,០០០$ (ពីរម៉ឺនបីពាន់) ដុល្លារអាមេរិក ហើយខ្លួនក៏បានបូមខ្សាច់ឱ្យទៅឈ្មោះ [redacted] កុសល ចំនួន១០ (ដប់) សាឡាង់ផងដែរ បើគិតជាម៉ែត្រគីបបានប្រហែលជា៤០,០០០(បួនម៉ឺន) ទៅ៥០,០០០(ប្រាំម៉ឺន) ម៉ែត្រគូប ស្មើនឹងសាច់ប្រាក់ប្រហែលជា៥០,០០០$ (ប្រាំម៉ឺន)ដុល្លារអាមេរិក។ មូលហេតុដែលខ្លួនឈប់បូមខ្សាច់ឱ្យឈ្មោះ [redacted] កុសល ព្រោះគាត់មិនបានទូទាត់ប្រាក់ឱ្យខ្លួនក្នុងរយៈពេល៣៤(សាមសិបបួន)ថ្ងៃ ដោយខ្លួនក៏បានជូនដំណឹងទៅឱ្យគាត់តាមមធ្យោបាយផ្សេងៗ រហូតដល់មានការជូនដំណឹងជាលាយលក្ខអក្សរទៅឱ្យគាត់ដើម្បីអនុវត្តកាតព្វកិច្ចទៀត ប៉ុន្តែខ្លួនពុំបានទទួលការឆ្លើយតបមកវិញសោះ។ ចំពោះប្រាក់ដែលឈ្មោះ [redacted] កុសល បានកក់ចំនួន២៣,០០០$ (ពីរម៉ឺនបីពាន់) ដុល្លារអាមេរិក បើធៀបនឹងខ្សាច់ចំនួន១០ (ដប់) សាឡាង់ ដែលខ្លួនបានបូមឱ្យឈ្មោះ [redacted] កុសល គឺមិនសមតុល្យគ្នាឡើយ ហើយឈ្មោះ [redacted] កុសល ត្រូវជំពាក់ខ្លួនវិញ។ សូមបញ្ជាក់ថា ចំពោះម៉ាស៊ីនបូមខ្សាច់



Scanned with CamScanner

គឺមិនមែនជារបស់ខ្លួនទេ ដោយខ្លួនបានជួលម៉ាស៊ីនបូមខ្សាច់ពីដៃគូររកស៊ីជាមួយខ្លួន។ ខ្លួនមានតួនាទីបូមខ្សាច់ពីទន្លេមកដាក់លើសាឡង់ មិនមែនមានតួនាទីដឹកខ្សាច់ទេ ចំពោះការដឹកខ្សាច់ គឺជារឿងរបស់ឈ្មោះ [redacted] កុសល។ ចំណែកឯកិច្ចសន្យាដែលធ្វើដោយអ្នកតំណាងរបស់ខ្លួនឈ្មោះ [redacted] សារ៉េត គឺខ្លួនទទួលស្គាល់ទាំងស្រុងមិនកែប្រែនោះទេ។

**២-ជនជាប់ចោទឈ្មោះ [redacted] សុខគង់ បានឆ្លើយថា÷** កាលពីថ្ងៃកើតហេតុ តំណាងរបស់ខ្លួនឈ្មោះ [redacted] សារ៉េត ពិតជាបានចុះកិច្ចសន្យាជាមួយឈ្មោះ [redacted] សុខា ដែលជាតំណាងរបស់ឈ្មោះ [redacted] កុសល ប្រាកដមែន ដោយនៅក្នុងកិច្ចសន្យាបានកំណត់ពីបំរាម កាលកក់ប្រាក់ និងការទូទាត់ប្រាក់។ ទាក់ទងនិងកិច្ចសន្យានេះ ភាគីខាងខ្លួន មានកាតព្វកិច្ចផ្គត់ផ្គង់ម៉ាស៊ីនបូមខ្សាច់ពីកណ្តាលទន្លេ បូមឱ្យឈ្មោះ [redacted] កុសល ឱ្យទាន់ផែនការ ដោយក្នុង០១ (មួយ)ថ្ងៃ ត្រូវបូមខ្សាច់ឱ្យបានចំនួន៥,០០០ (ប្រាំពាន់) ម៉ែត្រគូប ប៉ុន្តែប្រសិនបើបូមពុំបានគ្រប់ចំនួនក៏ត្រូវតែគិត៥,០០០ (ប្រាំពាន់) ម៉ែត្រគូបដែរ។ ខ្លួនទទួលបានប្រាក់ពីឈ្មោះ [redacted] កុសល ចំនួន២៣,០០០$ (ពីរម៉ឺនបីពាន់)ដុល្លារអាមេរិក ដោយចំនួន១៥,០០០$ (មួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ជាប្រាក់កក់ ហើយនៅពេលបញ្ចប់កិច្ចសន្យា ខ្លួននឹងប្រគល់ឱ្យឈ្មោះ [redacted] កុសល វិញ និងចំនួន៨,០០០$ (ប្រាំបីពាន់)ដុល្លារអាមេរិក ជាប្រាក់ដែលខ្លួនខ្ចីពីឈ្មោះ [redacted] កុសល សម្រាប់ជួសជុលម៉ាស៊ីន ទូទាត់ថ្លៃប្រេង និងថ្លៃកម្មករ។ សូមបញ្ជាក់ថា ខ្លួនទទួលស្គាល់ថាពិតជាមានទំនាក់ទំនងជាមួយឈ្មោះ [redacted] កុសល ក្នុងការផ្គត់ផ្គង់បូមខ្សាច់ឱ្យគាត់ពិតមែន គឺគាត់ជាអ្នកជួលម៉ាស៊ីនខ្លួន មិនមែនដឹកខ្សាច់ឱ្យគាត់ទេ។ ក្នុងកិច្ចសន្យាមិនបានថាផ្គត់ផ្គង់ដឹកជញ្ជូនទេ គឺផ្គត់ផ្គង់តែមាស៊ីនបូមឱ្យទាន់ផែនការប៉ុណ្ណោះ។

**៣-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កុសល បានឆ្លើយថា÷** កាលពីថ្ងៃកើតហេតុ ខ្លួនបានឱ្យឈ្មោះ [redacted] ស៊ិនប៉ោ ផ្ទេរការបូមខ្សាច់សំណង់ឱ្យឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ ធ្វើការងារបន្តដែលឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ ត្រូវមានសាឡង់ចំនួន០២(ពីរ)គ្រឿង អ៊ីកណ្តាល និងអ៊ីកៀន ហើយធ្វើយ៉ាងម៉េចឱ្យខ្សាច់មកខាងលើចំនួន២,០០០(ពីរពាន់) ម៉ែត្រគូប សម្រាប់ដេប៉ូរបស់ខ្លួនមួយ បន្ទាប់មកឈ្មោះ [redacted] សុខា និងឈ្មោះ [redacted] ស៊ិនប៉ោ បានផ្ទេរប្រាក់ដែលខ្លួនបានកក់ចំនួន ១០,០០០$ (មួយម៉ឺន)ដុល្លារអាមេរិក ឱ្យទៅឈ្មោះ លឹម បណ្ឌិត និងឈ្មោះ ម៉ាត់ សារ៉េត។ ក្រោយពីផ្ទេរការងាររួចហើយ ឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ បានខ្ចីប្រាក់ពីខ្លួនជាបន្តបន្ទាប់ សរុបទាំងអស់ចំនួន២៣,៣០០$ (ពីរម៉ឺនបីពាន់បីរយ)ដុល្លារអាមេរិកបន្ថែមទៀត លុះក្រោយមកឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ តែងតែគេចវេសពីខ្លួនរហូត។ សូមបញ្ជាក់ថា ពេលដែលខ្លួនមិនទាន់បានដាក់មេការ ពេលនោះឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ ក៏មិនទាន់មានសម្ភារៈអ៊ីកៀននៅឡើយទេ ពួកគាត់បានសុំរកម៉ូយមកដាក់ឱ្យខ្លួន ដោយហៅសាឡង់តាមដេប៉ូផ្សេងៗ។ ចំពោះសាឡង់របស់ដេប៉ូផ្សេងៗ ដែលឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ នាំមកបូមខ្សាច់ពីឡូតិ៍របស់ខ្លួនចំនួន ១៧(ដប់ប្រាំ ពីរ)



Scanned with CamScanner

សាឡាង់ បានប្រហែលជា១៥,០០០ (មួយម៉ឺនប្រាំពាន់) ទៅ១៧,០០០ (មួយម៉ឺនប្រាំពីរពាន់) ម៉ែត្រគូប គឺឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ មិនទាន់បានទូទាត់មកឱ្យខ្លួននៅឡើយទេ។ ខ្លួនសូមទាមទារប្រាក់កក់ចំនួន២២,៣០០$ (ពីរម៉ឺនពីរពាន់បីរយដុ)ល្លារអាមេរិក, ទាមទារលុយខ្សាច់ចំនួន១១ (ដប់មួយ) សាឡាង់ ប្រហែលជា៧,០០០$ (ប្រាំពីរពាន់)ដុល្លារអាមេរិក, ទាមទារការខាតបង់ពេលវេលាជាងមួយខែស្មើ២៦៤,០០០$ (ម្ភៃប្រាំមួយម៉ឺនបួនពាន់)ដុល្លារអាមេរិក ដែលខ្លួនត្រូវសងឱ្យចិនវិញ។

៤- សាក្សីឈ្មោះ [redacted] សារ៉េត បានឆ្លើយថា÷ កាលពីថ្ងៃកើតហេតុ ឈ្មោះ [redacted] បណ្ឌិត ពិតជាបានឱ្យខ្លួនធ្វើកិច្ចសន្យាជាមួយឈ្មោះ [redacted] សុខា ពិតប្រាកដមែន ដោយឈ្មោះ [redacted] សុខា ជួលអ្នកកណ្ដាលមួយទៅបូមខ្សាច់នៅព្រែកពោធិ៍ ខេត្តកំពង់ចាម។ ក្នុងកំឡុងពេល០១(មួយ)អាទិត្យដំបូង ខ្លួនឃើញមានការបូមខ្សាច់ហើយ ប៉ុន្តែខ្លួនមិនដឹងថាបូមទៅណាទេ។

៥- សាក្សីឈ្មោះ [redacted] មុន្នីរម្យ បានឆ្លើយថា÷ កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០ ឈ្មោះ [redacted] កុសល បានឱ្យខ្លួនទៅចាំអ្វី លុះនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ក៏ចាប់ផ្ដើមមានសាឡាង់ចូលមក ដោយថ្ងៃខ្លះមានសាឡាង់ចំនួន០១(មួយ)គ្រឿង និងថ្ងៃខ្លះមានសាឡាង់ចំនួន០២(ពីរ)គ្រឿង ពេលដែលសាឡាង់ចូលមកក្នុងឡូតិ៍របស់ឈ្មោះ [redacted] កុសល ខ្លួនតែងតែសួរទៅកាន់អ្នកយកសាឡាង់មកថា សាឡាង់ខាងណា? ដេប៉ូណា? ទើបអ្នកយកសាឡាង់បានឆ្លើយថា ខាងឈ្មោះ [redacted] បណ្ឌិត ប៉ុន្តែមិនបានប្រាប់ថា ខាងដេប៉ូណាឡើយ ទើបខ្លួនបានតេទៅសួរឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] កុសល លុះទទួលបានការអនុញ្ញាតទើបខ្លួនឱ្យចូល។ សូមបញ្ជាក់ថា ក្នុងអំឡុងពេលបូមខ្សាច់នោះ គឺមានសាឡាង់ចំនួន១១ (ដប់មួយ)គ្រឿង បានប្រហែលជា១០,២២០ (មួយម៉ឺនពីររយម្ភៃ) ម៉ែត្រគូប។

៦- សាក្សីឈ្មោះ [redacted] វឿង បានឆ្លើយថា÷ ខ្លួនជាមិត្តភ័ក្ត្ររបស់ឈ្មោះ [redacted] កុសល ហើយខ្លួនបានណែនាំឈ្មោះ [redacted] ស៊ិនប៉ោ ឱ្យស្គាល់ឈ្មោះ [redacted] កុសល ដើម្បីរកស៊ីខ្សាច់ជាមួយគ្នា។ ដំបូងឈ្មោះ តាប៉ោ គាត់បានធ្វើកិច្ចសន្យាជាមួយឈ្មោះ [redacted] កុសល ក្នុងការធ្វើខ្សាច់ស្អុយ និងខ្សាច់សំណង់ ហើយឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ សុំឈ្មោះ [redacted] កុសល ធ្វើខ្សាច់ដែរ ដោយធ្វើបន្តពីឈ្មោះ [redacted] ស៊ិនប៉ោ លើកការងារខ្សាច់សំណង់។ ការងាររបស់ឈ្មោះ [redacted] ស៊ិនប៉ោ ដែលបានចុះកិច្ចសន្យាជាមួយឈ្មោះ [redacted] កុសល គឺឈ្មោះ [redacted] ស៊ិនប៉ោ ត្រូវមានអ្នកកណ្ដាល អ្នកកៀន និងសាឡាង់ ដោយធ្វើខ្សាច់នៅរកាកោង។ ពេលផ្ទេរការងារខ្លួនក៏នៅទីនោះដែរ ដោយឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] គង់ ធ្វើយ៉ាងម៉េចឱ្យខ្សាច់ដល់ដេប៉ូ ដោយគិតតម្លៃ២.៤ (ពីរចុចបួន)ដុល្លារអាមេរិក។ សូមបញ្ជាក់ថា ខ្លួនពុំបានដឹងថាឈ្មោះ [redacted] ស៊ិនប៉ោ និងឈ្មោះ [redacted] បណ្ឌិត បានដឹងពីសម្ភារៈទាំងអស់ដើម្បីឱ្យខ្សាច់ដល់ដេប៉ូនោះទេ ។

៧- សាក្សីឈ្មោះ [redacted] ស៊ិនប៉ោ បានឆ្លើយថា÷ ខ្លួនឈ្មោះ [redacted] ប៉ោ មិនមែនឈ្មោះ [redacted] ស៊ិនប៉ោ ទេ។ ដំបូងឡើយខ្លួនជាមួយឈ្មោះ [redacted] សុខា គឺជាអ្នកធ្វើកិច្ចសន្យាជាមួយឈ្មោះ [redacted] កុសល ដោយ

ទទួលគំរោងពីឈ្មោះ [redacted] កុសល ធ្វើខ្សាច់លុប និងខ្សាច់សំណង់ ហើយដើម្បីឱ្យបានខ្សាច់លុប នឹងខ្សាច់សំណង់ គឺខ្លួនត្រូវមានសាឡង់ដឹកខ្សាច់ ម៉ាស៊ីនអ៊ូកៀន និងម៉ាស៊ីនអ៊ូកណ្តាល ប៉ុន្តែនៅពេលដែលខ្លួនទទួលការងារពីឈ្មោះ [redacted] កុសល ខ្លួនពុំទាន់ធ្វើការងារខ្សាច់សំណង់ទេ បន្ទាប់មកឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ មកសុំធ្វើខ្សាច់សំណង់ ជាមួយឈ្មោះ [redacted] កុសល ដោយបានជួបគ្នាផ្ទាល់ នៅហាងកាហ្វេមួយកន្លែង គឺមានរូបខ្លួន, ឈ្មោះ [redacted] កុសល, ឈ្មោះ [redacted] បណ្ឌិត, ឈ្មោះ [redacted] សុខគង់, ឈ្មោះ [redacted] ងៀង និងឈ្មោះ មុន្នីរម្យ ហៅ ហេង សរុបទៅគឺ០៦(ប្រាំមួយ)នាក់។ នៅពេលដែលខ្ញុំទទួលការងារពីឈ្មោះ [redacted] កុសល គឺគាត់បានកក់លុយឱ្យមកខ្លួនចំនួន១៥,០០០$ (មួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ប៉ុន្តែខ្លួនបានប្រគល់ប្រាក់ឱ្យទៅឈ្មោះ [redacted] សារ៉េត វិញ។ សូមបញ្ជាក់ថា ខ្លួនជាអ្នកទទួលការងារដំបូងពីឈ្មោះ [redacted] កុសល មូលហេតុដែលខ្លួនផ្ទេរការងារទៅឱ្យឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ អត់បានធ្វើជាលាយល័ក្ខអក្សរ ដោយសារតែខ្លួនមិនទាន់បានធ្វើខ្សាច់សំណង់ទេ។ នៅពេលផ្ទេរគឺខ្លួនបានណែនាំឈ្មោះ [redacted] បណ្ឌិត ទៅឱ្យឈ្មោះ [redacted] កុសល ស្គាល់គ្នាហើយ តែចំពោះទំនាក់ទំនងអ្វីទៀត គឺខ្លួនអត់ដឹងទេ ព្រោះពេលខ្លួនបានផ្ទេរការងាររួចហើយ ខ្លួនអត់បានទំនាក់ទំនងអ្វីទៀតទេ ។

**៨-មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា÷** ឆ្លងតាមការសួរដេញដោលនាពេលសវនាការ ខ្លួនសុំឯកភាពទាំងស្រុងនូវសេចក្តីថ្លែងការណ៍របស់កូនក្តីខ្លួនឈ្មោះ [redacted] កុសល និងសុំរក្សាខ្លឹមសារ និងការទាមទារដូចមាននៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងសេចក្តីសន្និដ្ឋានការពារ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១ ឱ្យនៅដដែល ហើយសូមសំណូមពរ យោងតាមអង្គហេតុ និងអង្គច្បាប់ រួមទាំងសេចក្តីសន្និដ្ឋានដែលខ្លួនបានដាក់ជូន សូមលោកចៅក្រមមេត្តាពិនិត្យពិចារណាតាមគតិច្បាប់ និងសូមទាមទារដូចជា បង្គាប់ឱ្យឈ្មោះ [redacted] សុងគង់ និងឈ្មោះ [redacted] បណ្ឌិត សងប្រាក់ចំនួន២៨,៨៥៩$ (ពីរម៉ឺនប្រាំបីពាន់ប្រាំបីរយហាសិបប្រាំបួន)ដុល្លារអាមេរិក, ទាមទារសំណងជម្ងឺចិត្ត និងពស្យនកម្មនានាចំនួន២៦៤,០០០$ (ម្ភៃប្រាំមួយម៉ឺនបួនពាន់)ដុល្លារអាមេរិក ដោយប្រាក់នេះគិតទៅលើការពិន័យ២,០០០ (ពីរពាន់) ម៉ែត្រគូប ក្នុង០១(មួយ)ថ្ងៃៗ ដោយក្នុងមួយគីបតម្លៃ២.២០ (ពីរចុចម្ភៃ) ដុល្លារអាមេរិក និងសូមឱ្យផ្តន្ទាទោសឈ្មោះ [redacted] សុខគង់ និងឈ្មោះ [redacted] បណ្ឌិត ទៅតាមនីតិវិធីច្បាប់ ។

**៩- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ÷** ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួចមក ឃើញថា ជនជាប់ចោទទាំងពីរនាក់ខាងលើបានឆ្លើយសារភាពហើយថា ខ្លួនពិតជាបានចុះកិច្ចសន្យាបូមខ្សាច់សំណង់ឱ្យជនរងគ្រោះ ពិតប្រាកដមែន ដោយត្រូវបូមចំនួន២,០០០ (ពីរពាន់) ម៉ែត្រគូបក្នុង០១ (មួយ)ថ្ងៃ និងបានខ្ចីប្រាក់ពីជនរងគ្រោះជាបន្តបន្ទាប់ សរុបចំនួន២៣,៣០០$ (ពីរម៉ឺនបីពាន់បីរយ)ដុល្លារអាមេរិក ដោយបានប្រាប់ជនរងគ្រោះថា ខ្ចីលុយយកទៅជួសជុលម៉ាស៊ីនបូមខ្សាច់ លុះពេលទទួលបានប្រាក់ ជនជាប់ចោទទាំងពីរនាក់បានព្យាយាមគេចវេសពីជនរងគ្រោះរហូត។

ហេតុដូចនេះ តំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់ដូចនៅក្នុងដីកាសន្និដ្ឋានស្ថាពរ **លេខ១២៣៩ ដកសព ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១** ទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

**១០-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា÷** ក្រោយពីបានពិនិត្យ និងសិក្សាចាប់ពីដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរ ដំណាក់កាលជំនុំជម្រះ រហូតដល់ពេលដេញដោលនាពេលសវនាការ គឺឃើញថាចម្លើយរបស់ឈ្មោះ ស្រី កុសល ទាំងបីលើកតែងតែប្រែប្រួល និងបានលេចចេញនូវអង្គហេតុផ្សេងថ្មីទៀតដោយមិនពាក់ព័ន្ធទៅនឹងពាក្យបណ្តឹង និងមិនពាក់ព័ន្ធទៅនឹងកំណត់ហេតុសួរចម្លើយនៅដំណាក់កាលតំណាងអយ្យការ។ យល់ឃើញថា អង្គហេតុខាងលើនេះ គឺវិវាទផ្នែករដ្ឋប្បវេណីសុទ្ធសាធ ដោយកើតចេញពីកិច្ចសន្យា ម្យ៉ាងវិញទៀត ក៏មិនបានរកឃើញនូវធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់មកលើកូនក្តីខ្លួនដែរ។ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំទៅតុលាការមេត្តាសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ ដោយហេតុថាអង្គហេតុទាំងអស់កើតឡើងពីកិច្ចសន្យា ហើយកិច្ចសន្យាទាំងអស់នោះក៏បានដាក់ឱ្យតុលាការពិនិត្យពិចារណារួចរាល់ហើយ ដូច្នេះពុំមានទំនាក់ទំនង ឬបច្ច័យជាហេតុ ឬជាផល ដែលធ្វើការចោទប្រកាន់កូនក្តីខ្លួន ដូច្នេះក្នុងនាមជាមេធាវីការពារសិទ្ធិសូមស្នើសុំលោកចៅក្រមមេត្តាសម្រេចឱ្យកូនក្តីខ្ញុំរួចផុតពីបទចោទតាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**១១- សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] បណ្ឌិត÷** ខ្លួនសូមឱ្យតុលាការពិនិត្យលើការចោទប្រកាន់ រួមទាំងសូមឱ្យតុលាការរកយុត្តិធម៌ នឹងលើកលែងបទចោទប្រកាន់ខ្លួន ។

**១២- សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខគង់÷** ខ្លួនសូមសំណូមពរឱ្យតុលាការពិនិត្យទៅលើកិច្ចសន្យាជាមួយគាត់ ហើយអ្វីដែលខ្លួនធ្វើមិនបានទៅបោកប្រាស់គាត់នោះទេ គឺធ្វើតាមកិច្ចសន្យា និងសូមឱ្យតុលាការរកយុត្តិធម៌ និងលើកលែងបទចោទប្រកាន់ខ្លួន ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទទាំងពីររូប
- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- ក្រោយពីបានស្តាប់សំដីចុងចក្រោយរបស់ជនជាប់ចោទ ។
- ក្រោយពីបានពិនិត្យភស្តុតាងនានា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងខេត្តកណ្ដាល យល់ឃើញថា**

១-កាលពីអំឡុងខែតុលា ឆ្នាំ២០២០ ឈ្មោះ [redacted] សុខគង់ ភេទប្រុស និងឈ្មោះ [redacted] បណ្ឌិត ភេទប្រុស បានទទួលម៉ៅការក្នុងការដឹកខ្សាច់សំណង់ឱ្យឈ្មោះ [redacted] កុសល ភេទប្រុស ដោយដឹកពីឃុំព្រែកពោធិ៍ ខេត្តកំពង់ចាម ឆ្ពោះទៅដេប៉ូខ្សាច់នៅភូមិកំពង់ព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្ដាល ក្នុងមួយថ្ងៃយ៉ាងតិចបំផុតចំនួន២,០០០(ពីរពាន់)ម៉ែត្រគូប ក្នុងតម្លៃ២.២$ (ពីរចុចពីរ)ដុល្លារអាមេរិកក្នុងមួយម៉ែត្រគូប។ ក្រោយពីឯកភាពព្រមព្រៀងគ្នា ឈ្មោះ [redacted] កុសល ក៏បានប្រគល់ប្រាក់កក់ចំនួន១០,០០០$ (មួយម៉ឺន)ដុល្លារអាមេរិក ទៅឱ្យឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ ហើយក៏បានសន្យាថាបីថ្ងៃក្រោយនឹងចាប់ផ្ដើមធ្វើការដឹកខ្សាច់យកទៅដាក់នៅដេប៉ូខ្សាច់របស់ឈ្មោះ [redacted] កុសល នៅភូមិកំពង់ព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្ដាល។ លុះដល់ថ្ងៃការកំណត់ដឹកខ្សាច់ ស្រាប់តែឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ បានសុំពន្យាពេល ដោយប្រាប់ថាម៉ាស៊ីនបូមខ្សាច់សម្រាប់បាញ់ឡើងកំពុងខូច និងបានខ្ចីប្រាក់ឈ្មោះ [redacted] កុសល បន្ថែមចំនួន៥,០០០$ (ប្រាំពាន់)ដុល្លារអាមេរិក ដើម្បីយកទៅទិញគ្រឿងបន្លាស់ពីប្រទេសវៀតណាម ព្រមទាំងសន្យាថា មួយអាទិត្យទៀតនឹងដឹកខ្សាច់ឱ្យឈ្មោះ [redacted] កុសល។ លុះដល់ថ្ងៃកំណត់ឈ្មោះទាំងពីរនាក់មិនបានដឹកខ្សាច់ឱ្យឈ្មោះ [redacted] កុសល ទេ ហើយថែមទាំងខ្ចីប្រាក់បន្ថែមចំនួន ១០,០០០$ (មួយម៉ឺន)ដុល្លារអាមេរិក ដោយប្រាប់ថាគ្រឿងបន្លាស់ម៉ាស៊ីនបូមខ្សាច់មានតម្លៃថ្លៃ។ បន្ទាប់ពីបានទទួលប្រាក់លើកចុងក្រោយនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០ ឈ្មោះ [redacted] កុសល បានតេទូរស័ព្ទទៅអ្នកទាំងពីរខាងលើ ប៉ុន្តែអ្នកទាំងពីរនោះ មិនព្រមលើកទូរស័ព្ទ និងបានព្យាយាមគេចវេសរហូត ។

២-យល់ឃើញថា តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បណ្ឌិត បានបញ្ជាក់ថា÷ កាលពីថ្ងៃកើតហេតុ ខ្លួនពិតជាបានឱ្យអ្នកតំណាងឈ្មោះ [redacted] សារ៉េត ធ្វើកិច្ចសន្យាម៉ៅការបូមខ្សាច់ជាមួយឈ្មោះ [redacted] សុខា ជាអ្នកតំណាងឱ្យឈ្មោះ [redacted] កុសល ដោយនៅក្នុងកិច្ចសន្យាបានកំណត់ក្នុង០១(មួយ)ម៉ែត្រគូប តម្លៃ០.២៧$ (សូន្យចុចម្ភៃប្រាំពីរ)ដុល្លារអាមេរិក ហើយក្នុង០១ (មួយ)ថ្ងៃ ត្រូវបូមឱ្យបានចំនួន៥,០០០(ប្រាំពាន់) ម៉ែត្រគូប ប្រសិនបើបូមមិនបានគ្រប់ចំនួនក៏ត្រូវតែគិត៥,០០០(ប្រាំពាន់) ម៉ែត្រគូបដែរ បើគិតជាសាឡង់បានប្រហែលជា០៤(បួន) ទៅ០៥(ប្រាំ) តាមទំហំសាឡង់ជាក់ស្ដែង និងបានកំណត់រយៈពេល០២(ពីរ)ឆ្នាំ រួមទាំងត្រូវធ្វើការកក់ប្រាក់ចំនួន១៥,០០០$ (មួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ប្រាកដមែន។ រហូតដល់ពេលបច្ចុប្បន្នខ្លួនបានទទួលប្រាក់ពីឈ្មោះ [redacted] កុសល ចំនួន២៣,០០០$ (ពីរម៉ឺនបីពាន់)ដុល្លារអាមេរិក ហើយខ្លួនក៏បានបូមខ្សាច់ឱ្យទៅឈ្មោះ [redacted] កុសល ចំនួន១០(ដប់) សាឡុង់ផងដែរ បើគិតជាម៉ែត្រគីបបានប្រហែលជា៤០,០០០ (បួនម៉ឺន) ទៅ៥០,០០០ (ប្រាំម៉ឺន) ម៉ែត្រគូប ស្មើនឹងសាច់ប្រាក់ប្រហែលជា៥០,០០០$ (ប្រាំម៉ឺន)ដុល្លារអាមេរិក។ មូលហេតុដែលខ្លួនឈប់បូមខ្សាច់ឱ្យឈ្មោះ [redacted]

កុសល ព្រោះគាត់មិនបានទូទាត់ប្រាក់ឱ្យខ្លួនក្នុងរយៈ ពេល៣៤(សាមសិបបួន)ថ្ងៃ ដោយខ្លួនក៏បានជូនដំណឹងទៅឱ្យគាត់តាមមធ្យោបាយផ្សេងៗ រហូតដល់មានការជូនដំណឹងជាលាយលក្ខអក្សរទៅឱ្យគាត់ដើម្បីអនុវត្តកាតព្វកិច្ចទៀត ប៉ុន្តែខ្លួនពុំបានទទួលការឆ្លើយតបមកវិញសោះ។ ចំពោះប្រាក់ដែលឈ្មោះ [redacted] កុសល បានកក់ចំនួន២៣,០០០$ (ពីរម៉ឺនបីពាន់)ដុល្លារអាមេរិក បើធៀបនឹងខ្សាច់ចំនួន១០ (ដប់) សាឡង់ ដែលខ្លួនបានបូមឱ្យឈ្មោះ [redacted] កុសល គឺមិនសមតុល្យគ្នាឡើយ ហើយឈ្មោះ [redacted] កុសល ត្រូវជំពាក់ខ្លួនវិញ។ សូមបញ្ជាក់ថា ចំពោះម៉ាស៊ីនបូមខ្សាច់ គឺមិនមែនជារបស់ខ្លួនទេ ដោយខ្លួនបានជួលម៉ាស៊ីនបូមខ្សាច់ពីដៃគូរកស៊ីជាមួយខ្លួន។ ខ្លួនមានតួនាទីបូមខ្សាច់ពីទន្លេមកដាក់លើសាឡង់ មិនមែនមានតួនាទីដឹកខ្សាច់ទេ ចំពោះការដឹកខ្សាច់ គឺជារឿងរបស់ឈ្មោះ [redacted] កុសល។ ចំណែកឯកិច្ចសន្យាដែលធ្វើដោយអ្នកតំណាងរបស់ខ្លួនឈ្មោះ [redacted] សារ៉េត គឺខ្លួនទទួលស្គាល់ទាំងស្រុងមិនកែប្រែនោះទេ។

**៣-យល់ឃើញថា** តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សុខគង់** បានបញ្ជាក់ថា÷ កាលពីថ្ងៃកើតហេតុ តំណាងរបស់ខ្លួនឈ្មោះ [redacted] សារ៉េត ពិតជាបានចុះកិច្ចសន្យាជាមួយឈ្មោះ [redacted] សុខា ដែលជាតំណាងរបស់ឈ្មោះ [redacted] កុសល ប្រាកដមែន ដោយនៅក្នុងកិច្ចសន្យាបានកំណត់ពីបំរាម កាលកក់ប្រាក់ និងការទូទាត់ប្រាក់។ ទាក់ទងនិងកិច្ចសន្យានេះ ភាគីខាងខ្លួន មានកាតព្វកិច្ចផ្គត់ផ្គង់ម៉ាស៊ីនបូមខ្សាច់ពីកណ្តាលទន្លេ បូមឱ្យឈ្មោះ [redacted] កុសល ឱ្យទាន់ផែនការ ដោយក្នុង០១ (មួយ)ថ្ងៃ ត្រូវបូមខ្សាច់ឱ្យបានចំនួន៥,០០០ (ប្រាំពាន់) ម៉ែត្រគូប ប៉ុន្តែប្រសិនបើបូមពុំបានគ្រប់ចំនួនក៏ត្រូវតែគិត៥,០០០ (ប្រាំពាន់) ម៉ែត្រគូបដែរ។ ខ្លួនទទួលបានប្រាក់ពីឈ្មោះ [redacted] កុសល ចំនួន២៣,០០០$ (ពីរម៉ឺនបីពាន់)ដុល្លារអាមេរិក ដោយចំនួន១៥,០០០$ (មួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ជាប្រាក់កក់ ហើយនៅពេលបញ្ចប់កិច្ចសន្យា ខ្លួននឹងប្រគល់ឱ្យឈ្មោះ [redacted] កុសល វិញ និងចំនួន៨,០០០$ (ប្រាំបីពាន់)ដុល្លារអាមេរិក ជាប្រាក់ដែលខ្លួនខ្ចីពីឈ្មោះ [redacted] កុសល សម្រាប់ជួសជុលម៉ាស៊ីន ទូទាត់ថ្លៃប្រេង និងថ្លៃកម្មករ។ សូមបញ្ជាក់ថា ខ្លួនទទួលស្គាល់ថាពិតជាមានទំនាក់ទំនងជាមួយឈ្មោះ [redacted] កុសល ក្នុងការផ្គត់ផ្គង់បូមខ្សាច់ឱ្យគាត់ពិតមែន គឺគាត់ជាអ្នកជួលម៉ាស៊ីនខ្លួន មិនមែនដឹកខ្សាច់ឱ្យគាត់ទេ។ ក្នុងកិច្ចសន្យាមិនបានថាផ្គត់ផ្គង់ដឹកជញ្ជូនទេ គឺផ្គត់ផ្គង់តែមាស៊ីនបូមឱ្យទាន់ផែនការប៉ុណ្ណោះ។

**៤-យល់ឃើញថា** តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កុសល បានបញ្ជាក់ថា÷ កាលពីថ្ងៃកើតហេតុ ខ្លួនបានឱ្យឈ្មោះ [redacted] ស៊ិនប៉ោ ផ្ទេរការបូមខ្សាច់សំណង់ឱ្យឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ ធ្វើការងារបន្ត ដែលឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ ត្រូវមានសាឡង់ចំនួន០២(ពីរ)គ្រឿង អ៊ូកណ្តាល និងអ៊ូកៀន ហើយធ្វើយ៉ាងម៉េចឱ្យខ្សាច់មកខាងលើចំនួន២,០០០ (ពីរពាន់) ម៉ែត្រគូប សម្រាប់ដេប៉ូរបស់ខ្លួនមួយ បន្ទាប់មកឈ្មោះ [redacted] សុខា និងឈ្មោះ [redacted] ស៊ិនប៉ោ បានផ្ទេរប្រាក់ដែលខ្លួនបានកក់ចំនួន១០,០០០$ (មួយម៉ឺន)ដុល្លារអាមេរិក ឱ្យទៅឈ្មោះ [redacted] បណ្ឌិត



Scanned with CamScanner

និងឈ្មោះ [redacted] សារ៉េត។ ក្រោយពីផ្ទេរការងាររួចហើយ ឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ បានខ្ចីប្រាក់ពីខ្លួនជាបន្តបន្ទាប់ សរុបទាំងអស់ចំនួន២៣,៣០០$ (ពីរម៉ឺនបីពាន់បីរយ)ដុល្លារអាមេរិក បន្ថែមទៀត លុះក្រោយមកឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ តែងតែគេចវេសពីខ្លួនរហូត។ សូមបញ្ជាក់ថា ពេលដែលខ្លួនមិនទាន់បានដាក់មេការ ពេលនោះឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ ក៏មិនទាន់មានសម្ភារៈអ៊ូកៀននៅឡើយទេ ពួកគាត់បានសុំរកម៉ូយមកដាក់ឱ្យខ្លួន ដោយហៅសាឡុងតាមដេប៉ូផ្សេងៗ។ ចំពោះសាឡុងរបស់ដេប៉ូផ្សេងៗដែលឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ នាំមកបូមខ្សាច់ពីឡូតិ៍របស់ខ្លួនចំនួន ១៧(ដប់ប្រាំ ពីរ) សាឡុង បានប្រហែលជា១៥,០០០(មួយម៉ឺនប្រាំពាន់) ទៅ១៧,០០០(មួយម៉ឺនប្រាំពីរពាន់) ម៉ែត្រគូប គឺឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ មិនទាន់បានទូទាត់មកឱ្យខ្លួននៅឡើយទេ។ ខ្លួនសូមទាមទារប្រាក់កក់ចំនួន២២,៣០០$ (ពីរម៉ឺនពីរពាន់បីរយដុ)ល្លារអាមេរិក, ទាមទារលុយខ្សាច់ចំនួន១១(ដប់មួយ) សាឡុង ប្រហែលជា៧,០០០$ (ប្រាំពីរពាន់) ដុល្លារអាមេរិក, ទាមទារការខាតបង់ពេលវេលាជាងមួយខែស្មើ២៦៤,០០០$ (ម្ភៃប្រាំមួយម៉ឺនបួនពាន់) ដុល្លារអាមេរិក ដែលខ្លួនត្រូវសងឱ្យចិនវិញ។

**៥- យល់ឃើញថា** ផ្អែកតាមអង្គហេតុខាងលើ, ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បណ្ឌិត, ជនជាប់ចោទឈ្មោះ [redacted] សុខគង់ , សាក្សីឈ្មោះ [redacted] សារ៉េត, សាក្សីឈ្មោះ [redacted] មុន្នីរម្យ, សាក្សីឈ្មោះ [redacted] អៀង, សាក្សីឈ្មោះ [redacted] ស៊ិនប៉ោ, ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] កុសល និងពាក្យបណ្ដឹងរួមទាំងភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿង គឺអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ លឹម បណ្ឌិត និងជនជាប់ចោទឈ្មោះ [redacted] សុខគង់ ពិតជាបានប្រព្រឹត្តបទល្មើស អំពើ វិលោភលើទំនុកចិត្ត ពិតប្រាកដមែន ដោយជនជាប់ចោទទាំងពីររូបបានតែបំបាត់ទ្រព្យសម្បត្តិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នាំឱ្យខូចប្រយោជន៍ ដោយសារជនជាប់ចោទមានភារកិច្ចប្រគល់សងនូវព្រទ្យសម្បត្តិទាំងអស់ មកឱ្យដើមបណ្ដឹងវិញ។

**៦- យល់ឃើញថា** មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] បណ្ឌិត ភេទប្រុស កើតឆ្នាំ១៩៩៣ ជនជាតិខ្មែរ និងជនជាប់ចោទឈ្មោះ [redacted] សុខគង់ ភេទប្រុស កើតឆ្នាំ១៩៨៩ ជនជាតិខ្មែរ ពីបទ÷ **វិលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិព្រែកសំរោង១ សង្កាត់តាខ្មៅ ក្រុង តាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ។

**៧- យល់ឃើញថា** អំពើល្មើស និងសកម្មភាពរបស់ជនជាប់ចោទធ្វើឱ្យខូចសណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈ ប៉ះពាល់ដល់ទ្រព្យសម្បត្តិ និងផលប្រយោជន៍របស់បុគ្គលឯកជនដែលច្បាប់បានការពារ និងតម្រូវឱ្យផ្តន្ទាទោស។



Scanned with CamScanner

៨-យល់ឃើញថា ពេលធ្វើសកម្មភាព ជនជាប់ចោទមានសតិបញ្ញាស្មារតីគ្រប់គ្រាន់ ប្រព្រឹត្តអំពើល្មើសច្បាប់រហូតសម្រេចតាមបំណងរបស់ខ្លួន ហើយជានីតិជនដែលមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។

៩-យល់ឃើញថា ÷ ជនរងគ្រោះបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងសូមទាមទារប្រាក់កក់ចំនួន២២,៣០០$ (ពីរម៉ឺនពីរពាន់បីរយ)ដុល្លារអាមេរិក រួមទាំងទាមទារប្រាក់ខ្សាច់ចំនួន១១ (ដប់មួយ) សាឡង់ ប្រហែលជា៧,០០០$ (ប្រាំពីរពាន់)ដុល្លារអាមេរិក និងទាមទារការខាតបង់ពេលវេលាជាងមួយខែស្មើ២៦៤,០០០$ (ម្ភៃប្រាំមួយម៉ឺនបួនពាន់)ដុល្លារអាមេរិក ពីជនជាប់ចោទទាំងពីរ ឃើញថា ការទាមទារនេះមានភាពត្រឹមត្រូវតាមច្បាប់ គប្បីតុលាការធ្វើការពិចារណាស្របតាមបញ្ញត្តិមាត្រា១៣ និងមាត្រា១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

១. ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] បណ្ឌិត ភេទប្រុស អាយុ ២៨ឆ្នាំ(កើតឆ្នាំ១៩៩៣) និងឈ្មោះ [redacted] សុខគង់ ភេទប្រុស អាយុ ៣២ឆ្នាំ(កើតឆ្នាំ១៩៨៩) ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន ១៨ (ដប់ប្រាំបី) ខែ ។

ពីបទ÷ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិព្រែកសំរោង១ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

២. បង្គាប់ឱ្យឈ្មោះ [redacted] បណ្ឌិត និងឈ្មោះ [redacted] សុខគង់ រួមគ្នាសងនូវប្រាក់កក់ចំនួន ២២,៣០០$ (ពីរម៉ឺនពីរពាន់បីរយ)ដុល្លារអាមេរិក, លុយថ្លៃខ្សាច់ ១១សាឡង់ ចំនួន ៧,០០០$ (ប្រាំពីរពាន់)ដុល្លារអាមេរិក និងប្រាក់ខាតបង់ពេលវេលាចំនួន១៨០,០០០$ (ដប់ប្រាំម៉ឺន)ដុល្លារអាមេរិក ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កុសលភេទប្រុស។ ការប្តឹងទាមទារលើសពីនេះត្រូវច្រានចោល។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] បណ្ឌិត ជនជាប់ចោទឈ្មោះ [redacted] សុខគង់ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កុសល ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner